# អំពីសិទ្ធិជំនួយទូទៅ និងការទទួលខុសត្រូវ

**គោលបំណងនៃសំណៅនេះ**: សំណៅនេះប្រាប់អ្នកអំពីសិទ្ធិជំនួយទូទៅ និងការទទួលខុសត្រូវរបស់អ្នកនៅពេលអ្នកដាក់ពាក្យស្នើសុំ ឬទទួលជំនួយទូទៅ (GR) ។ អ្នកត្រូវតែពិនិត្យឡើងវិញ និងយល់ដឹងទាំងនេះនៅពេលអ្នកដាក់ពាក្យស្នើសុំជំនួយទូទៅ GR ។

**ប្រសិនបើអ្នកចុះហត្ថលេខាលើសំណៅនេះ** អ្នកយល់ស្របថាអ្នកយល់ដឹងអំពីសិទ្ធិជំនួយទូទៅ និងការទទួលខុសត្រូវរបស់អ្នក។

**ប្រសិនបើអ្នកមិនបានចុះហត្ថលេខាលើសំណៅនេះ** ពាក្យស្នើសុំ ជំនួយទូទៅ GR របស់អ្នកឥតបានបំពេញឲ្យចប់សព្វគ្រប់ ។

**នៅពេលអ្នកដាក់ពាក្យស្នើសុំ ឬអ្នកទទួលជំនួយទូទៅ (GR) អ្នកមានអំពីសិទ្ធិ:**

1. ដើម្បីត្រូវបានអនុគ្រោះដោយសេចក្តីគួរសម ដោយសេចក្តីរាប់អាន និងការគោរព។
2. ដើម្បីត្រូវបានការសេវាដោយគ្មានការទាក់ទងទៅនឹង ពូជសាសន៍ ព័ណសម្បុរ, លិទ្ធិ សញ្ជាតិដើម សាសនា ការចូលជាសមាជិកគណៈបក្សនយោបាយ, ស្ថានភាពអាពាហ៍ពិពាហ៍, ភេទ, ភាពអសមត្ថភាព ឬ វ័យ ។
3. ដើម្បីដាក់ពាក្យបណ្តឹងបើសិនអ្នកជឿថាអ្នកត្រូវបានគេរើសអើង។
4. ដើម្បីស្នើសុំការសម្រួលមួយ បើសិនអ្នកមានពិការភាពហើយត្រូវការ ដាក់ពាក្យស្នើសុំផលប្រយោជន៍ ឬការបំពេញតម្រូវការណាមួយសម្រាប់ជំនួយទូទៅ GR ។ អ្នកអាចស្នើសុំជំនួយដោយ:
    - អ្នកអាចទាក់ទងទៅសុំជំនួយពីក្រសួងសេវាសង្គមកិច្ចសាធារណៈ (DPSS) ទៅអ្នកកាន់សំណុំរឿងណាមួយ ។
    - ឬទាក់ទងតាមលេខទូរស័ព្ទ ADA លេខទូរស័ព្ទទំនាក់ទំនងជាបន្ទាន់នៅ (844) 586-5550 ។
5. ដើម្បីទទួលបានព័ត៌មានពីការិយាល័យ DPSS មានអ្នកបកប្រែភាសារបស់អ្នក ។
6. មានអ្នកបកប្រែនៅពេលអ្នកទៅការិយាល័យ DPSS:
    - ដោយឥតគិតថ្លៃ។
    - ដើម្បីឱ្យមានអ្នកបកប្រែមួយអ្នកអានធ្វើដំណើរទៅកាន់ឯការិយាល័យ DPSS ក៏បានដែរ។ អ្នកអាចប្រើកម្មវិធីបកប្រែផ្ទាល់របស់អ្នកបើសិនអ្នកជ្រើសរើស។
7. ដើម្បីដាក់ពាក្យស្នើសុំសម្រាប់ផលប្រយោជន៍ជំនួយទូទៅ GR ហើយពាក្យស្នើសុំរបស់អ្នកបានដំណើរការល្អក្នុងលក្ខណៈទាន់ពេលវេលា ។
8. ការដកចេញនូវពាក្យស្នើសុំអំពីជំនួយទូទៅ GR របស់អ្នកនៅពេលណាមួយមុន ខោនធីបានកំណត់ បើសិនអ្នកមានសិទ្ធិទទួលបានផលប្រយោជន៍។
9. ដើម្បីទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរមួយ បើសិនជំនួយទូទៅ GR របស់អ្នក ដែលត្រូវបានបដិសេធ ។
    - ការជូនដំណឹងនឹងរួមទាំងហេតុផលដែលអ្នកដែលត្រូវបានបដិសេធអត្ថប្រយោជន៍។
    - ប្រសិនបើអ្នកមិនយល់ស្របអ្នកអាចជំទាស់ការបដិសេធនេះដោយ:
        - និយាយជាមួយអ្នកកាន់សំណុំរឿង DPSS របស់អ្នក
        - និយាយជាមួយអ្នកគ្រប់គ្រង DPSS របស់អ្នក
        - និយាយទៅអ្នកទាក់ទងផ្នែកតវ៉ាជំទាស់លើការបដិសេធ DPSS ។
10. ដើម្បីទទួលបានការជូនដំណឹងមួយដែលបានសរសេរយ៉ាងហោចណាស់ចំនួនដប់ថ្ងៃមុនពេលដែលផលប្រយោជន៍របស់អ្នកត្រូវបានកាត់បន្ថយ ឬបញ្ឈប់ដោយរួមបញ្ចូលទាំងមូលហេតុ សម្រាប់ការកាត់បន្ថយ ឬការមិនមានការបន្តទៅទៀតនេះ។
    - សេចក្តីជូនដំណឹងនេះនឹងរួមទាំង:
        - ហេតុផលសមរម្យល្អ សម្រាប់ការផ្លាស់ប្តូរ។
        - កាលបរិច្ឆេទសម្រាប់សវនាការអំពីការផ្លាស់ប្តូរ។
    - បើសិនអ្នកមិនយល់ព្រមនេះ អ្នកអាចជំទាស់នឹងការផ្លាស់ប្តូរសវនាការរបស់អ្នក។
        - អ្នកមានសិទ្ធិនាំសាក្សី ឬភស្តុតាងមកកាន់សវនាការនេះ។
        - មន្ត្រីដែលធ្វើជាអធិបតីក្នុងសវនាការនឹងត្រូវបានជាគណបក្សអព្យាក្រឹត្យ។
11. ដើម្បីជំទាស់នឹងសេចក្តីជូនដំណឹងណាមួយដែលអ្នកត្រូវការដើម្បីបង់ប្រាក់ត្រឡប់ទៅខោនធីវិញដោយសារតែការចំណាយលើសនៅពេលធ្វើការសវនាការ។
    - អ្នកមានសិទ្ធិក្នុងការនាំយកសាក្សី ឬ ភស្តុតាងក្នុង សវនាកានេះ បើសិនអ្នកជ្រើសរើសយកវា ។
    - មន្ត្រីដែលដឹកនាំសវនាការ នឹងជាគណបក្សអព្យាក្រឹត្យ។
12. ដើម្បីជ្រើសរើសនរណាម្នាក់ដែលអ្នកជឿទុកចិត្តដើម្បីដំណើរការក្នុងការសម្រេចចិត្ត និងទាក់ទងទៅបុគ្គលិក DPSS អំពីសំណុំរឿងរបស់អ្នក។
    - បុគ្គលនេះក៏អាចជួយអ្នកបំពេញសំណៅ និងរាយការណ៍ពីការផ្លាស់ប្តូរសម្រាប់អ្នក។
    - ប្រសិនបើអ្នកជ្រើសរើសនរណាម្នាក់បុគ្គលនេះនឹងជា "អ្នកតំណាងពេញសិទ្ធិ" របស់អ្នក។
    - អ្នកអាចនិយាយជាមួយបុគ្គលិក DPSS របស់អ្នកដើម្បីសិក្សាបន្ថែមអំពីអ្នកតំណាងលើច្បាប់ដែលមានសិទ្ធិ។
13. ដើម្បីជ្រើសរើសនរណាម្នាក់ដែលអ្នកជឿទុកចិត្តដើម្បី និងការប្រើប្រាស់ផលប្រយោជន៍ GR របស់អ្នក។
    - មនុស្សដែលអ្នក ជ្រើសរើស នឹងក្លាយជាអ្នកកាន់កាតជំនួសបាន។ "ម្ចាស់ប័ណ្ណជំនួស" ។
    - សម្រាប់ព័តមានបន្ថែមអ្នកអាចសួរទៅអ្នកកាន់សំណុំរឿងស្តីអំពី"ម្ចាស់ប័ណ្ណជំនួស" របស់អ្នក ។

14. ដើម្បីមានព័ត៌មានក្នុងកំណត់ត្រាលើសំណុំរឿងរបស់អ្នកដែលបានរក្សាទុកជាការសម្ងាត់។ មានតែមនុស្សខាងក្រោមនេះដែលអាចចូលពិនិត្យមើលកំណត់ត្រាសំណុំរឿងរបស់អ្នកបានគឺ:
    - ដោយភ្នាក់ងារខោនធី ឬភ្នាក់ងារនៃរដ្ឋ ដែលទទួលបន្ទុកខាងគ្រប់គ្រងសំណុំរឿង ឬភ្នាក់ងារផ្ទាល់ពីជំនួយទូទៅ GR ។
    - ដោយខោនធីនៃគណៈវិនិច្ឆ័យបឋម ។
    - ដោយប៉ូលីស។
15. ដើម្បីពិនិត្យមើលកំណត់ត្រាសំណុំរឿងរបស់អ្នកជាមួយនឹងសំណុំរឿងលើកលែងតែ 'ព័ត៌មានឯកសិទ្ធិការពារ' ណាមួយជាព័ត៌មានដែលការិយាល័យ DPSS ដែលទទួលបានថា:
    - ការិយាល័យ DPSS មិនមានសិទ្ធិចែករំលែកទេ។
    - ដើម្បីរក្សាទុកព័ត៌មានជាសម្ងាត់អំពីនរណាម្នាក់ផ្សេងទៀត។
16. ដើម្បីទទួលបានជំនួយការពី DPSS ប្រសិនបើអ្នកចង់ចុះឈ្មោះបោះឆ្នោត។
17. ដើម្បីទទួលបានសេវាសង្គ្រោះបន្ទាន់ប្រសិនបើអ្នកមានលក្ខណៈសម្បត្តិទទួល:
    - មានលក្ខណៈសម្បត្តិទទួលបាន ជំនួយទូទៅ GR ។
    - ការរង់ចាំការយល់ព្រមសម្រាប់ជំនួយទូទៅ GR ។
    - ការមិនមានលក្ខណៈសម្បត្តិទទួលបានកម្មវិធី CalFresh ។

    សេវាសង្គ្រោះបន្ទាន់រួមមាន:
    - សក្ខីប័ត្រសម្រាប់បង់ថ្លៃសណ្ឋាគារ។
    - សក្ខីប័ត្រសម្រាប់បង់ថ្លៃម្ហូបអាហារ។
    - សក្ខីប័ត្របង់សម្រាប់ថ្លៃដឹកជញ្ជូន សម្រាប់កិច្ចប្រជុំដែលទាក់ទងនឹងសេវាកិច្ចការ DPSS ។
18. ដាក់ពាក្យស្នើសុំអត្ថប្រយោជន៍ Medi-Cal ។
19. ដាក់ពាក្យស្នើសុំអត្ថប្រយោជន៍ CalFresh ។
20. សួររកការណែនាំផ្នែកច្បាប់ដោយឥតគិតថ្លៃ ឬជួយជាមួយសវនាការដោយទាក់ទងការិយាល័យជំនួយខាងផ្លូវច្បាប់។
21. ជ្រើសរើសការរស់នៅរបស់អ្នក និងទីកន្លែងនៅក្នុងខោនធី Los Angeles ។
22. ប្រើប្រាស់ PO Box (ប្រអប់សម្រាប់ដាក់សំបុត្រ) ឬអាសយដ្ឋានផ្ញើផ្សេងទៀតនៅក្នុងខោនធី Los Angeles ដើម្បីទទួលសំបុត្ររបស់អ្នក។
23. ការប្រើការិយាល័យខ័ណ្ឌដែលអ្នកបានដាក់ពាក្យស្នើសុំធ្វើជាអាស័យដ្ឋានផ្ញើរសំបុត្ររបស់អ្នកដែលទាក់ទងនឹងកិច្ចការ DPSS ។ ប្រសិនបើអ្នកជ្រើសយកដំណើរការនេះអ្នកត្រូវតែទៅទទួលយកសំបុត្រនៅទីនេះយ៉ាងហោចណាស់មួយដងក្នុងមួយសប្តាហ៍។
24. ស្នើសុំឱ្យមានការផ្លាស់ប្តូរអ្នកកាន់សំណុំរឿង DPSS ឬអ្នកកាន់សំណុំរឿងជំនួយទូទៅសម្រាប់ (GROW) ដែលត្រូវបានចាត់តាំងឱ្យអ្នក។

**នៅពេលអ្នកដាក់ពាក្យស្នើសុំ ឬទទួលជំនួយទូទៅ (GR), <u>ការទទួលខុសត្រូវ</u>របស់អ្នកគឺ:**

1. ដើម្បីផ្តល់ជូនទៅ DPSS នូវឯកសារទាំងអស់ដែលចាំបាច់ដើម្បីកំណត់ បើសិនអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលជំនួយទូទៅ GR ។
2. ដើម្បីផ្តល់ជូនទៅ DPSS នូវឯកសារទាំងអស់ដែលត្រូវការដើម្បីកំណត់ចំនួនអត្ថប្រយោជន៍ជំនួយទូទៅ របស់អ្នក។
3. ដើម្បីអនុវត្តតាមតម្រូវការទាំងអស់សម្រាប់ជំនួយទូទៅ GR ។
4. ដើម្បីរក្សាឲ្យការណាត់ជួបរបស់អ្នក ។
    - សេចក្តីជូនដំណឹងទៅដល់អ្នកកាន់សំណុំរឿង DPSS របស់អ្នក បើសិនអ្នកមិនអាចធ្វើការណាត់ជួបនេះ ។
5. ដើម្បីអនុវត្តតាមការដាក់ពាក្យស្នើសុំជំនួយទូទៅ សម្រាប់ឱកាសរកការងារក្នុងកម្មវិធី GROW ។
    - អ្នកនឹងទទួលបានការលើកលែង បើសិនអ្នកមិនអាចធ្វើការងារដោយសារស្ថានភាពសុខភាពផ្លូវកាយ ឬសុខភាពសតិអារម្មណ៍។
        - អ្នកត្រូវការផ្តល់សំបុត្រភ័ស្តុតាងពីអ្នកផ្តល់សេវាសុខភាពផ្លូវកាយ ឬសុខភាពសតិអារម្មណ៍។
        - អ្នកកាន់សំណុំរឿង DPSS នឹងពន្យល់អំពីរបៀបផ្តល់សំបុត្រភស្តុតាងនៅពេល ដែលអ្នកដាក់ពាក្យស្នើសុំជំនួយទូទៅ GR ។
6. ដាក់ពាក្យស្នើសុំ និងទទួលយកប្រាក់ចំណូលដែលអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលជំនួយ ។ ឧទាហរណ៍រួមមាន:
    - ប្រាក់ធានារ៉ាប់រងអ្នកអត់ការងារធ្វើ។
    - ផលប្រយោជន៍ពិការភាព។
    - ប្រាក់ចំណូលសូស្យាល់ស៊ីគួរីទី ។
7. ដើម្បីពិនិត្យសំបុត្ររបស់អ្នកឲ្យបានទៀងទាត់ យ៉ាងហោចណាស់រៀងរាល់សប្តាហ៍ម្តង សម្រាប់ការជូនដំណឹងពីការិយាល័យ DPSS ទាក់ទងនឹងផលប្រយោជន៍របស់អ្នក។
    - បើសិនអ្នកគ្មានទីជម្រក និងមិនមានអាស័យដ្ឋានផ្ញើរសំបុត្រ អ្នកត្រូវតែទៅពិនិត្យសំបុត្រនៅឯការិយាល័យ GR ។
    - អ្នកអាចពិនិត្យមើលសម្រាប់ការជូនដំណឹង DPSS នៅលើ DPSS អត្ថប្រយោជន៍របស់អ្នក ឥឡូវនេះ (YBN) នៅគេហទំព័រ dpss.lacounty.gov ។

8. ដើម្បីបំពេញសំណៅឲ្យបានចប់សព្វគ្រប់ និងដាក់ស្នើរបាយការណ៍ប្រចាំត្រីមាសជំនួយទូទៅ QR 7 LA 7 ដោយថ្ងៃទីដប់ខែថ្ងៃដែលកំណត់ផ្ញើត្រឡប់មកវិញនោះទេ ។
   - ការយឺតយាវរបាយការណ៍ប្រចាំត្រីមាសជំនួយទូទៅ GR អាចបណ្តាលឱ្យផលប្រយោជន៍របស់អ្នកទៅជាយឺតពេល និង/ឬបញ្ឈប់។
   - អ្នកអាចបំពេញនិងដាក់ស្នើរបាយការណ៍ QR7-LA តាមរយៈប្រៃសណីយ៍ ឬ ដាក់ស្នើរបាយការណ៍តាម គេហទំព័រ YBN ។
   - ចូរកត់សម្គាល់ថាមនុស្សមួយចំនួនខ្លះនឹងមិនចាំបាច់បំពេញរបាយការណ៍ប្រចាំត្រីមាសជំនួយទូទៅ GR ទេ។ ចំពោះព័ត៌មានលំអិតបន្ថែមផ្សេងៗទៀត សូមទាក់ទងទៅអ្នកកាន់សំណុំរឿង DPSS របស់អ្នក ។

9. ដើម្បីរាយការណ៍ពីការផ្លាស់ប្តូរដែលអាចប្តូរបានផលប្រយោជន៍ជំនួយទូទៅ GR របស់អ្នកក្នុងរយៈពេល**ប្រាំថ្ងៃ**ចាប់ពីថ្ងៃការផ្លាស់ប្តូរដែលបានកើតឡើងនេះ។ អ្នកត្រូវរាយការណ៍អំពីការផ្លាស់ប្តូរទៅ:
   - មជ្ឈមណ្ឌលសេវាអតិថិជនតាមទូរស័ព្ទ 866-613-3777 ឬ
   - ដោយបំពេញឲ្យបានចប់សព្វគ្រប់របាយការណ៍ស្ថានភាពពាក់កណ្តាលត្រីមាសទី GR (QR3) <u>និង</u> QR 7-LA ។

   ការផ្លាស់ប្តូរដែលប៉ះពាល់ដល់អត្ថប្រយោជន៍ GR:
   - ប្រាក់ចំណូលថ្មីដែលរកបានថ្មីពី $203 ឬច្រើនជាងនេះក្នុងមួយខែសម្រាប់មនុស្សម្នាក់ៗ។
     - ប្រាក់ចំណូលដែលទទួលបានគឺប្រាក់ពីការងារគ្រប់ប្រភេទ។
   - ប្រាក់ចំណូលបានមកដោយមិនបានរកថ្មីគឺ $25 ឬច្រើនជាងនេះក្នុងមួយខែសម្រាប់មនុស្សម្នាក់ៗ។
     - ប្រាក់ចំណូលដែលបានមកដោយមិនបានធ្វើការគឺជាប្រាក់ដែលអ្នកទទួលបានពីក្រៅពីធ្វើការងារ ។ ឧទាហរណ៍រួមមាន:
       - ប្រាក់ធានារ៉ាប់រងអ្នកអត់ការងារធ្វើ។
       - ធានារ៉ាប់រងពិការភាពនៃរដ្ឋ។
       - ប្រយោជន៍ជំនួយពីអតីតយុទ្ធជន។
   - តើមាននរណាម្នាក់បានរើចូល ឬរើចេញពីសមាជិកក្នុងគ្រួសាររបស់អ្នក។
   - ការផ្លាស់ប្តូរនៃអាសយដ្ឋានប្រៃសណីយ៍។
   - អ្នកជាប់ពន្ធនាគារ ឬដោះលែងពីពន្ធនាគារ ។
   - តើនរណាម្នាក់ក្នុងសមាជិកគ្រួសាររបស់អ្នក ត្រូវរត់គៀសខ្លួនចេញដើម្បីជៀសវាងការកាត់ទោស ឬការឃុំឃាំង/ការផ្តន្ទាទោសនៃបទឧក្រិដ្ឋ។
   - ក្រសួងកិច្ចការសញ្ជាតូបនីយកម្ម និង អន្តោប្រវេសន៍នៃសហរដ្ឋអាមេរិកធ្វើការកំណត់សម្រាប់ នៃកម្មវិធី T ឬ U ទិដ្ឋាការ របស់អ្នក។

   កំណត់សម្គាល់: រាយការណ៍អំពីការផ្លាស់ប្តូរផ្សេងៗទៀតទាំងអស់លើរបាយការណ៍ប្រចាំត្រីមាសរបស់អ្នក។

10. ដើម្បីសងប្រាក់ទៅខោនធីវិញ បើសិនអ្នកទទួលបាន ផលប្រយោជន៍ដោយសារតែ:
    a) យើងបានធ្វើឲ្យមានកំហុសឬ
    b) អ្នកមិនមានលក្ខណៈសម្បត្តិទទួលបានជំនួយ។

    អ្នកអាចសងប្រាក់ត្រឡប់ឲ្យទៅខោនធីដោយ:
    - ប្រាក់ចេញឲ្យលើសនេះអាចត្រូវបានប្រមូលដោយកាត់បន្ថយប្រាក់ជំនួយទូទៅ GR របស់អ្នក។
    - ការមិនបន្តនៃការផ្តល់ឲ្យជំនួយទូទៅ GR ឬរយៈពេលមិនមានសិទ្ធទទួលបាន ។

**11.** ប្រសិនបើអ្នកដាក់ពាក្យស្នើសុំប្រាក់ចំណូលសូស្យាល់ស៊ីគួរីទី )SSI) /សូស្យាល់ស៊ីគួរីទីបន្ថែម )SSP), ប្រាក់ជំនួយទូទៅ GR នៃណាមួយដែលអ្នកទទួលបានអាចត្រូវកាត់ចេញពីមូលប្បទានប័ត្រដំបូង

ខ្ញុំបញ្ជាក់ថាខ្ញុំបានអាន ឬបានឱ្យនរណាម្នាក់អាន ឱ្យខ្ញុំខាងលើនេះហើយខ្ញុំយល់ និងយល់ព្រមទៅនឹងអំពីសិទ្ធិ និងការទទួលខុសត្រូវទាំងនេះ។

________________________________________

អ្នកដាក់ពាក្យស្នើសុំ / ហត្ថលេខាអ្នកទទួល ខែថ្ងៃឆ្នាំ

________________________________________

☐ ប្តី ឬប្រពន្ធ/ជាដៃគូរស់នៅជាមួយគ្នា / អ្នកតំណាងពេញលើច្បាប់ ខែថ្ងៃឆ្នាំ